# អភិបាលខេត្តកំពង់ឆ្នាំង ចែកមុងជ្រលក់ថ្នាំ ជូនដល់ប្រជាពលរដ្ឋចំនួន ៥០៨៧ នាក់

អភិបាលខេត្តកំពង់ឆ្នាំងលោក **ឡូច ម៉ារីម** កាលពីព្រឹកថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១១ បានធ្វើពិធីចែកមុងជ្រលក់មុងថ្នាំការពារជំងឺគ្រុនចាញ់ជូនដល់ប្រជាពលរដ្ឋចំនួន ៥០៨៧ នាក់ ត្រូវជា ១១៩៦ គ្រួសារដែលអញ្ជើញមកពីភូមិគោលដៅចំនួន ៤គឺ **ភូមិក្បាលដំរី ត្រពាំងចាន់ កណ្តាល និង ភូមិសន្លង់** ស្ថិត នៅក្នុងឃុំបរិបូរណ៍ ខេត្ត កំពង់ឆ្នាំង។

លោក **ឡូច ម៉ារីម** អភិបាលនៃគណៈអភិបាលខេត្តកំពង់ឆ្នាំង បានមានប្រសាសន៍ថាមុងជ្រលក់ថ្នាំ ដែលបានចែកជូនប្រជាពលរដ្ឋនាពេលនេះជាអំណោយដ៏ថ្លៃថ្លារបស់សម្តេចមហាសេនាធបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ។ជាមួយគ្នានេះដែរលោក **ឡូច ម៉ារីម** បានមាន ប្រសាសន៍ថា មុងជ្រលក់ថ្នាំដែលបានចែកជូនប្រជាពលរដ្ឋនាពេលនេះគឺជា យុទ្ធ

សាស្ត្រការពារទប់ស្កាត់ការរីករាលដាលនៃការចម្លង មេរោគគ្រុនចាញ់បាន យ៉ាងមានប្រសិទ្ធិភាពមួយក្នុងការ អនុវត្តន៍ជាពិសេសសំរាប់ប្រជាពលរដ្ឋ ដែលរស់នៅតំបន់ ងាយរងគ្រោះ និង ប្រឈមនឹងជំងឺគ្រុនចាញ់។



